# អនុស្សរណៈ

កាលបរិច្ឆេទ៖ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧

ជូនចំពោះ៖ សមាជិកទាំងអស់របស់អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា(គ.ស.ក)

**កម្មវត្ថុ៖ គាំទ្រដល់សមាជិករបស់ អង្គការគ.ស.ក ក្នុងការឆ្លើយតបនឹងតម្រូវការនិងផលវិបាកនៃច្បាប់ស្តីពីពន្ធដារ និងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO)និងច្បាប់នានាដែលពាក់ព័ន្ធ។**

អង្គការសមាជិកនៃអង្គការ គ.ស.កទាំងអស់ជាទីគោរព!

អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) សូមជំរាបជូនថា ដោយអនុលោមតាមកម្មវិធីមជ្ឈមណ្ឌលអភិបាលកិច្ច (GHP) ឆ្នាំ២០១៧-២០២១ ឯកសារលទ្ធផលនៃកិច្ចប្រជុំប្រចាំឆ្នាំលើកទី២៧ (ខែមីនា ឆ្នាំ២០១៧) និងសំណើពីសមាជិករបស់ខ្លួន សម្រាប់ឆ្លើយតបទៅនឹងតម្រូវការ និងផលវិបាកនៃការអនុវត្តច្បាប់នានាពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិល (CSO) ជាពិសេសច្បាប់ស្តីពីពន្ធដារ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល (LANGO) អង្គការគ.ស.ក បានបង្កើតភាពជាដៃគូយុទ្ធសាស្ត្រជាមួយក្រុមហ៊ុន DFDL និងអង្គការជំនួយផ្នែកច្បាប់កម្ពុជា (LAC) ដែលមានគោលបំណងគាំទ្រដល់អង្គការសមាជិក និងអង្គការដៃគូរបស់អង្គការគ.ស.កដូចខាងក្រោម៖

**<u>អនុស្សរណៈនៃការយោគយល់ (MoU) ជាមួយក្រុមហ៊ុន DFDL</u>**

ក្រុមហ៊ុន DFDL កំពុងធ្វើការងារជាមួយ អង្គការគ.ស.ក និងក្រុមការងារពន្ធដារអង្គការសង្គមស៊ីវិល (ដែលត្រូវបានបង្កើតឡើងដោយ អង្គការគ.ស.កតាំងពីឆ្នាំ២០១៦) ចាប់ពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៧ ដល់ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨ ដើម្បីផ្តល់ការគាំទ្រ/ប្រឹក្សាយោបល់ដោយឥតគិតថ្លៃដល់អង្គការជាសមាជិក តាមរយៈគោលបំណងធំៗចំនួនបី៖

1. បង្កើតការយល់ដឹងឲ្យបានច្បាស់លាស់អំពីកាតព្វកិច្ចពន្ធដារក្នុងប្រទេសកម្ពុជាដែលពាក់ព័ន្ធទៅនឹងសមាជិករបស់ អង្គការគ.ស.ក។
2. បង្កើតយុទ្ធសាស្ត្រមួយ ដើម្បីលើកទឹកចិត្តឲ្យមានការអនុលោមតាមច្បាប់ពន្ធ និងធ្វើឲ្យល្អប្រសើរបំផុតលើកាតព្វកិច្ចពន្ធ និងការរៀបចំផែនការពន្ធក្នុងចំណោមសមាជិករបស់ គ.ស.ក។ និង
3. រកឱកាសដើម្បីចូលរួមកិច្ចសន្ទនាជាមួយក្រសួង និង/ឬមន្ទីរពាក់ព័ន្ធ ដើម្បីទទួលបានការទទួលស្គាល់ឋានៈជាអង្គការសប្បុរសធម៌ "មិនស្វែងរកប្រាក់ចំណេញ" របស់អង្គការមិនមែនរដ្ឋាភិបាល



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
GPP 25/08/2015 24/08/2018
Symbol of Trust និមិត្តសញ្ញានៃភាពទុកចិត្ត

នីមួយៗ ដែលឆ្លុះបញ្ចាំងពីការអនុវត្តការងាររបស់ខ្លួន ដើម្បីជាប្រយោជន៍សាធារណៈ តាមរយៈការចូលរួមចំណែកក្នុងការអភិវឌ្ឍ និងសុខុមាលភាពរបស់ប្រជាជនកម្ពុជា។

**អនុស្សារណៈនៃការយោគយល់ (MoU) ជាមួយអង្គការជំនួយផ្នែកច្បាប់កម្ពុជា**

អនុស្សារណៈនេះនឹងសុពលភាពពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៨ និងគ្របដណ្តប់លើវិស័យប្រឹក្សាផ្នែកច្បាប់ ដើម្បីលើកកម្ពស់ចំណេះដឹងរបស់អង្គការជាសមាជិករបស់ អង្គការគ.ស.ក អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា និងអង្គការសហគមន៍មូលដ្ឋានអំពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីពន្ធដារ ច្បាប់ស្តីពីការងារ និងច្បាប់ដែលពាក់ព័ន្ធផ្សេងទៀត តាមរយៈការផ្តល់ព័ត៌មាន និងការអប់រំ ការតស៊ូមតិ និងភាពជាតំណាងសម្រាប់ស្ថាប័នទាំងឡាយដែលមានបញ្ហាផ្នែកច្បាប់អំពីប្រតិបត្តិការសកម្មភាពរបស់ខ្លួន។ អង្គការគ.ស.ក និងអង្គការជំនួយផ្នែកច្បាប់កម្ពុជា នឹងព្យាយាមផ្តល់សេវាទាំងនេះដោយឥតគិតថ្លៃ។

ក្នុងន័យនេះ អង្គការគ.ស.ក សូមអញ្ជើញអង្គការជាសមាជិកដែលជួបប្រទះបញ្ហាណាមួយ ហើយត្រូវការការជំនួយផ្នែកបច្ចេកទេសស្តីពីពន្ធដារ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីការងារ និងច្បាប់ដែលពាក់ព័ន្ធនានា សូមអញ្ជើញទាក់ទងទៅកាន់ជនបង្គោលដូចខាងក្រោម៖

**សម្រាប់ច្បាប់ស្តីពីពន្ធដារ៖**

- លោក Adam Glen អ្នកស្ម័គ្រចិត្តបម្រើការងារឲ្យក្រុមការងារពន្ធដារអង្គការសង្គមស៊ីវិលរបស់អង្គការគ.ស.ក។ អ៊ីមែល៖ adam-glen@hotmail.com / ទូរស័ព្ទដៃ៖ ០៨៥ ៣៨៩ ៩០៣។ រី
- លោក ឃន ប៊ុនថុង ប្រធានផ្នែកប្រតិបត្តិការរបស់ អង្គការគ.ស.ក។ អ៊ីមែល៖ bunthong.khorn@ccc-cambodia.org ទូរស័ព្ទដៃ៖ ០៧៧ ៨៧៣ ០០៧។

**សម្រាប់ច្បាប់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ដែលពាក់ព័ន្ធផ្សេងទៀត៖**

- លោក កែវ ឌីណា ប្រធានកម្មវិធីនៃអង្គការជំនួយផ្នែកច្បាប់កម្ពុជា។ អ៊ីមែលៈ lac_womenjustice@online.com.kh ទូរស័ព្ទដៃ៖ ០១២ ៨៨៧ ៨៨២។ រី
- លោក មី ណាក់ អ្នកគ្រប់គ្រងផ្នែកបង្កើតសម្ព័ន្ធ តស៊ូមតិ និងបង្កើតបណ្តាញនៃអង្គការ គ.ស.ក។ អ៊ីមែល៖ nac.mi@ccc-cambodia.org ទូរស័ព្ទ៖ ០១២ ៨៧៥ ៧៨១។

សូមអរគុណសម្រាប់ការបន្តគាំទ្ររបស់លោក លោកស្រីដល់ការងារ និងអាណិត្តរបស់ អង្គការគ.ស.ក។

ដោយក្តីគោរព

គ.ស.ក CCC COOPERATION COMMITTEE FOR CAMBODIA

លោក សឿង សារឿន
នាយកប្រតិបត្តិ អង្គការគ.ស.ក